**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៤៤៤/០៧ គ.ជ.ប.ស.ស.ក

# សេចក្តីសម្រេច

## ស្តីពីការប្រកាសទទួលស្គាល់ឯកឧត្តម សាយ មង្គល បេក្ខជនតំណាងរាស្ត្រពេញសិទ្ធិ លំដាប់ទី ០៣ របស់គណបក្ស ហ៊្វុនស៊ិនប៉ិច នៅមណ្ឌល ខេត្ត ពោធិ៍សាត់

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម នស/រកម/១២៩៧.០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- បានឃើញព្រះរាជក្រម ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- បានឃើញសេចក្តីសម្រេចលេខ ០៥.៣០១/០៣ គ.ជ.ប. ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ជាផ្លូវការការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។
- បានឃើញសេចក្តីសម្រេចលេខ ០៨.៥១៨/០៣ គ.ជ.ប. ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ ។
- បានឃើញសេចក្តីសម្រេចលេខ ៤៤១/០៧ គ.ជ.ប.ស.ស.ក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោត និងបេក្ខជនឈរឈ្មោះតំណាងរាស្ត្រគណបក្ស **ហ៊្វុនស៊ិនប៉ិច** ចេញពី មណ្ឌល **ខេត្ត ពោធិ៍សាត់** ។

## សម្រេច

**ប្រការ១** : ទទួលស្គាល់ឯកឧត្តម **សាយ មង្គល** ភេទប្រុស អាយុ ៤៤ ឆ្នាំ ជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្ស **ហ៊្វុនស៊ិនប៉ិច** មណ្ឌលខេត្ត **ពោធិ៍សាត់** ។

**ប្រការ២** : គណបក្សនយោបាយសាមី អគ្គលេខាធិការដ្ឋាន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ។

**ប្រការ៣** : សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ៊ឹម សួស្តី**

**ចម្លងទូលថ្វាយ**
- ព្រះមហាក្សត្រ

**ចម្លងជូន**
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- បណ្ណសារដ្ឋានជាតិ
- គណបក្សនយោបាយ " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ